ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ធនាគារជាតិ នៃ កម្ពុជា

# សេចក្តីថ្លែងការណ៍រួម
# រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា

នាពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ប្រជាកសិករបានជួបប្រទះបញ្ហាប្រឈម និងមានការលំបាកក្នុងការលក់ផលិតផលរបស់ខ្លួន ព្រមទាំងទទួលរងសម្ពាធហិរញ្ញវត្ថុ ដោយសារតម្លៃកសិផលបាននឹងបន្តធ្លាក់ចុះជាបន្តបន្ទាប់ ជាពិសេសថ្លៃស្រូវនៅដើមរដូវកាលនៃការប្រមូលផលស្រូវក្រអូប ដែលការធ្លាក់ថ្លៃនេះ បណ្តាលមកពីកត្តាសត្យានុម័តជាច្រើន រួមមានអស្ថិរភាពថ្លៃនៅលើទីផ្សារអន្តរជាតិ ។ ទន្ទឹមនោះ ការធ្លាក់ភ្លៀងយ៉ាងគំហុកនារយៈពេលជិតពីរសប្តាហ៍កន្លងមកនេះ ក៏អាចធ្វើឱ្យមានផលប៉ះពាល់ដល់គុណភាពផលិតផល និងការនាំចេញផងដែរ ប្រសិនបើកសិករ និងអាជីវករក្នុងវិស័យកសិកម្មមិនមានទុនសមស្របសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ក្នុងរដូវប្រមូលផលនេះ ។ ដើម្បីជួយដោះស្រាយ បញ្ហាសម្ពាធហិរញ្ញវត្ថុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា អំពាវនាវនិងលើកទឹកចិត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សូម ៖

១. បន្តការផ្តល់ឥណទាន និងបង្កើនទំហំឥណទានដល់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុន ឬពាណិជ្ជករប្រមូលទិញស្រូវ តាមលទ្ធភាពជាក់ស្តែង ដើម្បីបង្កើនលទ្ធភាពក្នុងការប្រមូលទិញស្រូវ កសិផល និងការកែច្នៃកសិផលគ្រប់ប្រភេទ សំដៅរួមចំណែករក្សាស្ថិរភាពថ្លៃស្រូវ-អង្ករ កសិផល និងទ្រទ្រង់ការកែច្នៃកសិផលនៅក្នុងប្រទេស ។

២. ពិនិត្យលទ្ធភាពអនុវត្តគោលនយោបាយទន់ភ្លន់ និងអនុគ្រោះ ចំពោះកសិករជួបប្រទះបញ្ហាជាក់ស្តែង ដែលមានឥណទានដល់កាលកំណត់សង ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាសង្ឃឹមនិងជឿជាក់ថា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការ ក្នុងការជួយសម្រាលដល់ទុក្ខលំបាករបស់ប្រជាកសិករ និងសម្រាលសម្ពាធហិរញ្ញវត្ថុក្នុងវិស័យកសិកម្ម ក្នុងកាលៈទេសៈលំបាកនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦